អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

*រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២១*

# សេចក្តីប្រកាសព័ត៌មាន

ក្នុងថ្ងៃនេះ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញសេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ក្នុងសំណុំរឿង ០០៣។ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ដោយបញ្ជូន មាស មុត ទៅជំនុំជម្រះ ដោយឡែកនៅក្នុងថ្ងៃតែមួយនេះដែរ សហចៅក្រមស៊ើបអង្កេតជាតិ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ប្រឆាំង មាស មុត (ដីកាសម្រេចលើកលែងចោទប្រកាន់)។

**ផ្នែកសម្រេចសេចក្តីរួម ដែលសម្រេចជាឯកច្ឆន្ទ ដោយអង្គបុរេជំនុំជម្រះ**

បន្ទាប់ពីពិនិត្យមើលលើសំណុំរឿងរួចមក អង្គបុរេជំនុំជម្រះបានសម្រេចថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ អាចទទួលយកបាន (កថាខណ្ឌ ៥១ និង ៥៣ នៃសេចក្តីពិចារណា) ចំណែកបណ្តឹងឧទ្ធរណ៍របស់សហមេធាវីការពារក្តី មាស មុត ត្រូវបានប្រកាសថាមិនអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) និង ២១ នៃវិធានផ្ទៃក្នុង (កថាខណ្ឌ ៧៤ និង ៧៧)។

ជាបញ្ហាបឋម អង្គបុរេជំនុំជម្រះបានពិចារណាថា ការចេញព្រមគ្នានូវដីកាដំណោះស្រាយពីរដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុសច្បាប់ ដោយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក (កថាខណ្ឌ ៧៨-១០៩)។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចបច្ចុប្បន្នបិទផ្លូវតវ៉ា។

**មតិរបស់ចៅក្រមជាតិ**

ផ្អែកតាមការប្រកាសជាឯកច្ឆន្ទរបស់អង្គបុរេជំនុំជម្រះ អំពីអនីត្យានុកូលភាព ពាក់ព័ន្ធការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា និងការណ៍ពិតដែលថា សហចៅក្រមស៊ើបអង្កេត មិនបានបញ្ជូនការខ្វែងយោបល់គ្នាក្នុងសំណុំរឿងបច្ចុប្បន្នទៅអង្គបុរេជំនុំជម្រះ ចៅក្រមជាតិបានពិចារណាថា ដីកាដំណោះស្រាយទាំងពីរ របស់សហចៅក្រមស៊ើបអង្កេត មានតម្លៃស្មើគ្នា ត្រូវតម្កល់ទុកជាបានការដូចគ្នា មានសុពលភាពដូចគ្នា (កថាខណ្ឌ ១១១-១១៥)។

បន្ថែមលើនេះ ចៅក្រមជាតិនៃអង្គបុរេជំនុំជម្រះបានពិចារណាថា សហចៅក្រមស៊ើបអង្កេតទាំងពីរ មានឋានៈស្មើគ្នា និងបើតាមគោលការណ៍សច្ចធារណ៍នៃនិរទោស មិនមានការអនុញ្ញាតឲ្យអង្គបុរេជំនុំជម្រះសម្រេចថា កិច្ចរបស់សហចៅក្រមស៊ើបអង្កេតមួយរូបណា មានឧត្តមភាពនោះទេ។ ហេតុដូច្នេះ ចៅក្រមជាតិយល់ឃើញ

ថា ដីកាដំណោះស្រាយទាំងពីរ នៅតែមានតម្លៃស្មើគ្នា ហើយសំណុំរឿង ០០៣ ប្រឆាំង មាស មុត គួររក្សាទុកនៅក្នុងបណ្ណាសាររបស់ អ.វ.ត.ក (កថាខណ្ឌ ១១៦-១១៨)។

**មតិរបស់ចៅក្រមអន្តរជាតិ**

ពាក់ព័ន្ធបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះបានសម្រេចតម្កល់មូលដ្ឋានបណ្តឹងឧទ្ធរណ៍ចំនួនពីរ ទាក់ទងនឹងកំហុងអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេតជាតិដែលមិនបានពិចារណាដោយចេតនា នូវភស្តុតាងដែលបានដាក់ក្នុងសំណុំរឿង នៅក្រោយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ (កថាខណ្ឌ ២២៧-២៤៤) និងមិនបានសម្រេចទៅលើអង្គហេតុទាំងអស់នៅក្នុងបណ្តឹងដែលខ្លួនបានទទួល (កថាខណ្ឌ ២៤៥-២៤៨)។ ចៅក្រមអន្តរជាតិយល់ឃើញថា ជាលទ្ធផល ដីកាសម្រេចលើកលែងចោទប្រកាន់ ត្រូវទុកជាមោឃៈ ដោយសារតែជាឯកសារនីតិវិធីដែលមិនពេញលេញ (កថាខណ្ឌ ២៤៩-២៥០) និងបានប្រកាសថា មូលដ្ឋានបណ្តឹងឧទ្ធរណ៍ដែលនៅសល់ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្លាយជាអសារឥតការ (កថាខណ្ឌ ២៥១-២៥២)។

ពាក់ព័ន្ធនឹងសុពលភាពនៃដីកាដំណោះស្រាយ ចៅក្រមអន្តរជាតិបានបញ្ជាក់បំភ្លឺថា ក្នុងករណីមានការមិនចុះសម្រុងគ្នា ដែលមិនអាចដោះស្រាយបាន រវាងសហចៅក្រមស៊ើបអង្កេតលើបញ្ហាថា តើត្រូវចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាសម្រេចលើកលែងចោទប្រកាន់ អធិបញ្ញាដែលមាននៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក តាមរយៈគោលការណ៍បន្តការចោទប្រកាន់ បង្ហាញតម្រូវថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវចេញតាមការស្នើឡើង (កថាខណ្ឌ ២៥៧ និង ២៦១)។ ហេតុដូច្នេះ ដីកាសម្រេចលើកលែងចោទប្រកាន់ ក្រៅពីមោឃៈលើអង្គសេចក្តីហើយនោះ ថែមទាំងបង្កើតជាការព្យាយាមលប់បំបាត់គោលជំហរដាក់ស្តែងនេះ ដែលដូច្នេះហើយបានចេញដោយហួសពីសិទ្ធិអំណាច (កថាខណ្ឌ ២៦២ និង២៨៤) ចំណែកឯដីកាបញ្ជូនរឿងទៅជំនុំជម្រះ នៅតែមានសុពលភាពជាចម្បង និងអនុលោមទៅតាមក្របខណ្ឌគតិយុត្តិជាធរមាន (កថាខណ្ឌ ២៦២ និង២៨៤)។

បន្ទាប់ពីបានអះអាងថា មាស មុត ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម (កថាខណ្ឌ៣៤០) ចៅក្រមអន្តរជាតិបានសន្និដ្ឋានថា អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង ត្រូវទទួលយកដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (កថាខណ្ឌ ៣៤២-៣៤៣)។

សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ អាចរកមើលបាននៅលើគេហទំព័រ៖
https://eccc.gov.kh/sites/default/files/documents/courtdoc/%5Bdate-in-tz%5D/D266_27_KH.pdf

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖
ឯកឧត្តម នេត្រ ភក្ត្រា
ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ
ទូរស័ព្ទលេខ៖ +៨៥៥ (០) ១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh